ISSR
អ៊ីនធើណេសិនណាល ស្គូល អហ្វ សៀមរាប
International School of Siem Reap

ព័ត៌មានពីសាលាបឋម
ខែមីនា ឆ្នាំ២០១៨
វ៉ុល:២

បោះផ្សាយលើកទី៧

សេចក្ដីជូនដំណឹងពីសាលាបឋម

ព័ត៌មាន អំពីកីឡា

សាលា នឹងរៀបចំកម្មវិធីកីឡាប្រចាំឆ្នាំ បីថ្ងៃ ចាប់ពីថ្ងៃទី២៨ ខែមីនា ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨។

<u>សម្រាប់ថ្ងៃទី២៨ ខែមីនា ថ្នាក់ចូលរួមមាន៖</u>

<u>ទីតាំងជន្លង់ Sport's Club</u>

ពីថ្នាក់ **Rec 2** ដល់ថ្នាក់ទី១

- ចាប់ពីម៉ោង **8:15** ដល់ម៉ោង **10:00am**

<u>សម្រាប់ថ្ងៃទី២៨ ខែមីនា ថ្នាក់ចូលរួមមាន៖</u>

<u>ទីតាំងជន្លង់ Sport's Club</u>

ពីថ្នាក់ទី២ ដល់ ថ្នាក់ទី៦

- ចាប់ពីម៉ោង **8:15** ដល់ម៉ោង **11:30am**

<u>សម្រាប់ថ្ងៃទី៣០ ខែមីនា ថ្នាក់ចូលរួមមាន៖</u>

<u>ទីតាំងបរិវេណក្នុងសាលាអន្តរជាតិ</u>

ពីថ្នាក់ **Nursery** ដល់ថ្នាក់ **Rec 1**

- ចាប់ពីម៉ោង **8:00** ដល់ម៉ោង **9:00am**

សូមលោក-លោកស្រីចូលរួមឱ្យបានគ្រប់ៗគ្នាដើម្បីលើកទឹកចិត្តដល់កូនៗក្នុងការលេងកីឡា។ សិស្សទាំងអស់នឹងមានភាពរីករាយក្នុងថ្ងៃប្រកួតផងដែរ។

កម្មវិធី School Fair

នាងខ្ញុំដែលជានាយកផ្នែកបឋមនៃសាលា សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅពីសំណាក់លោក-លោកស្រី ដែលបានចូលរួមកម្មវិធីសប្បុរសធម៌របស់សាលា ដើម្បីជួយដល់មន្ទីរពេទ្យកុមារអង្គរ និងមន្ទីរពេទ្យគន្ធបុប្ផាកន្លងទៅនេះ។ ឆ្នាំនេះកម្មវិធីមានភាពជោគជ័យជាច្រើន ហើយឃើញថាសិស្សទាំងអស់សប្បាយរីករាយ ពិសេសការចាប់រង្វាន់ ព្រមទាំងការដាក់លក់ក្នុងតូបនីមួយៗមានរបៀបរៀបរយ។ សូមថ្លែងអំណរគុណដល់លោក-លោកស្រីនឹងអ្នកឧបត្ថម្ភគ្រប់ៗគ្នា។ ជាលទ្ធផលយើងទទួលបាន ២០៣៦.00 ដុល្លារអាមេរិចពីកម្មវិធី។ ក្នុងខែឧសភា ឆ្នាំ២០១៨ ខាងមុខនេះ សាលានឹងមានការរៀបចំកម្មវិធី ហែលទឹកប្រណាំងប្រចាំឆ្នាំ ដើម្បីប្រមូលថវិកាសប្បុរធម៌ម្តងទៀត។

We are one,
But we are many.

អំពីការអញ្ជើញមកកាន់សាលាបឋមពីសំណាក់លោក-លោកស្រី

សិស្សទាំងអស់ទទួលបានភាពរីករាយ ព្រមទាំងការពេញចិត្តជាខ្លាំងនូវវត្តមានរបស់លោក-លោកស្រីដែលបានមកទស្សនាថ្នាក់រៀនរបស់ពួកគេ កាលពីថ្ងៃសុក្រ ទី២ ខែមីនាថ្មីៗនេះ។ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះការចូលរួមរបស់លោក-លោកស្រី ពិសេសបានស្វែងយល់អំពីការសិក្សារបស់កូនៗ ព្រមទាំងបានឃើញអំពីសកម្មភាពសិក្សាមួយចំនួនក្នុងថ្នាក់។ ជាមួយគ្នានេះ សាលាក៏ទទួលបានមតិយោបល់ដើម្បីស្ថាបនាមួយចំនួន ពីសំណាក់មាតាបិតាសិស្ស ដ៏មានសារៈសំខាន់សម្រាប់យកមកអនុវត្តន៍បន្ថែមក្នុងកម្មវិធីសិក្សារបស់យើងខ្ញុំ។ នាងខ្ញុំសូមថ្លែងអំណរគុណ!

សិស្សថ្នាក់ទី១ A បង្កើតខ្លែងក្នុងមុខវិជ្ជា ក្រោយបានសិក្សា។

សកម្មភាព សិស្សថ្នាក់ទី១ B កំឡុងពេលសឡុនៈកីឡ សិក្សានៅ Art-box

អំពីការប្រឡង

សិស្សានុសិស្សទាំងអស់នឹងប្រឡងនៅថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែមីនា លើមុខវិជ្ជា អក្សរសាស្ត្រអង់គ្លេស និង គណិតវិទ្យា។ ការប្រឡងនេះដើម្បីពិនិត្យលើសម្ភភាពសិក្សារបស់សិស្សកន្លងមក នឹងលទ្ធផលជោគជ័យជាក់ស្តែងរបស់ពួកគេ។ សូមមាតាបិតាសិស្សទាំងអស់ មេត្តាឱ្យកូនៗគេងឱ្យបានគ្រប់គ្រាន់ នឹងមកសាលាឱ្យបានទាន់ពេលវេលា ពិសេស ញ៉ាំអាហារដែលមានជាសុកភាព។ តាមការស្រាវជ្រាវបានបង្ហាញថា ក្មេងៗដែលទទួលទានមានជាសុកភាព គឺរៀនឆាប់ចាំបានច្រើន ដូចនេះ សូមលោក-លោកស្រីផ្តល់នូវអាហារសម្រន់ណាដែលមានជាសុកភាពដើម្បីសិស្ស អាចផ្តោតអារម្មណ៍សិក្សាបានច្រើន។

កម្មវិធី Summer School ២០១៨

កម្មវិធី Summer School ចាប់ផ្តើមចុះឈ្មោះហើយ។ សម្រាប់ព័ត៌មានលំអិត សូមសាកសួរផ្នែករដ្ឋបាលសាលា ឬ អានបន្ថែមក្នុងប្រដាសផ្សព្វផ្សាយ។ កម្មវិធីនេះ ចាប់ផ្តើមពីថ្ងៃចន្ទ ទី០២ ខែកក្កដា ដល់ថ្ងៃសុក្រ ទី២៧ ខែកក្កដា ឆ្នាំ២០១៨។

សាលានឹងធ្វើការឈប់សម្រាកចំនួនមួយថ្ងៃ គឺ**ថ្ងៃសុក្រ** ទី**១៦** ខែ**មីនា** ដើម្បីលោកគ្រូ អ្នកគ្រូ កែវិញ្ញាសារប្រឡង។ សម្រាប់លោកគ្រូ អ្នកគ្រូ ព្រមទាំងបុគ្គលិកទាំងអស់ នៅធ្វើការជាធម្មតា។

មានតែអាហារដែលមានជាសុកភាពទេ ដែលអនុញ្ញាតឱ្យយកមកសាលារៀន!

កម្មវិធី Star of the Month៖

សូមលោក-លោកស្រីអញ្ជើញចូលរួមកម្មវិធីនេះ ដែលចាប់ផ្តើមនៅម៉ោង **៨:00 ព្រឹក**៖
- ថ្ងៃអង្គារ៍ ទី**០៣** ខែមេសា , ចូលរួមដោយថ្នាក់ Nursery-Year 1 (ថ្នាក់ Nursery សម្តែង) ។
- ថ្ងៃពុធ ទី**០៤** ខែមេសា , ចូលរួមដោយថ្នាក់ទី២ ដល់ទី៦ (ថ្នាក់ទី Yr3A សម្តែង) ។

សិស្សទាំងអស់ខំហ្វឹកហាត់យ៉ាងសកម្ម និងត្រៀមខ្លួនដើម្បីធ្វើការសម្តែងបានល្អ

កម្មវិធីមើលថែក្មេងពេលរសៀលសម្រាប់ថ្នាក់ Reception និងថ្នាក់ Nursery បានចាប់ដំណើរការហើយ។ ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍សូមអញ្ជើញមកសាសួរព័ត៌មាននៅការិយាល័យរដ្ឋបាលសាលា។